# ការសំភាសន៍ជាលើកទី២របស់លោកពូ ឌិន ជឿន

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះឌិន ជឿន

## ការសង្ខេបជាលើកទី២របស់លោកពូ ឌិន ជឿន

លោកពូ ឌិន ជឿន
កើតគាត់រៀនបានត្រឹមថ្នាក់ទី២ហើយគាត់ឥឡូវមិនបានចាំអានសរសេរអក្សរខ្មែរទេ
ហើយគាត់មានប្រពន្ធពីរហើយដោយសារប្រពន្ធមុនគាត់មានអ្នកថ្មី ទឹមបានត្រូវលែងលះគ្នា
ច្រើនឆ្នាំកន្លងមកបានពូរៀបការមានប្រពន្ធមួយទៀត!!
ហើយគាត់មានកូន២នាក់ជាមួយប្រពន្ធមុនហើយប្រពន្ធក្រោយអត់មានកូនទេ!!ហើយកូនគាត់
ត្រឹមតែអាយុ១២ឆ្នាំមានប្រពន្ធ គឺក្មេងខ្លាំងណាស់!!លោកពូបានកើតទាន់ជំនាន់លន់
នល់ហើយត្រូវបានរត់គេចគ្រាប់បែកហើយនៅក្នុងជំនាន់ប៉ុល
ពតគាត់បានឃើញគេសម្លាប់មុនដោយអារករហ្នឹងធាងត្នោតនឹងឬស្សី
ហើយគាត់ត្រូវជិតបានហូបនំបញ្ចុកដែលគេដាក់ថ្នាំបំពុល
តែដោយសារកងទ័ពវៀតណាមមកជួយរំដោះទាន់ទើបអត់បានហូប។ហើយក៏បានរួចខ្លួនរហូ
តមកដល់សព្វថ្ងៃ។

កៈ
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់លោកពូដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់
លោកពូជាលើកទី២ នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា
ជាអ្នកសំភាសន៍អំពីជីវប្រវត្តិនៅក្នុងថ្ងៃនេះពួកយើងសំភាសន៍គឺនៅក្នុងថ្ងៃទី២៧ ខែមិនា
ឆ្នាំ២០១៨។ ការសំភាសន៍នេះមានទីតាំងស្ថិតនៅក្នុងភូមិព្រែកហូរខាងលិច សង្កាត់ព្រែកហូរ
ក្រុងតាខ្មៅ ខេត្តកណ្ដាល
ប្រទេសកម្ពុជា។អ៊ីចឹងនាងខ្ញុំសូមចាប់ផ្ដើមសំភាសន៍អំពីជីវប្រវត្តិរបស់លោកពូដែលពេលមុន
គាត់អត់ដែលបានរៀបរាប់អំពីជីវប្រវត្តិរបស់គាត់ទាំងអស់។អ៊ិចឹងលោកពូសូមប្រាប់ឈ្មោះរប
ស់លោកពូម្ដងទៀ តបាា៎??

ខៈ ឈ្មោះ ឌិន ជឿន។

កៈ  លោកពូសំរាប់ការសិក្សារបស់លោកពូលោកពូបានសិក្សាដល់ថ្នាក់ទីប៉ុន្មានដែរ?

ខៈ  អត់បានរៀនសោះម៉ង។

កៈ ហ្ញ៎ពូប្រាប់ពេលមុនដែរ។

ខៈ  អត់ទេបានត្រឹមថ្នាក់ទី២ដែរតែរៀនទៅចេះតែឈឺឈប់ទៅ។

កៈ ហ្ញ៎អ៊ីចឹងបានរៀនដែរ!!

ខៈ  បាទ!!

កៈ មិនមែនអត់ទេ!!

ខៈ  បាទ!!គិតតែឈឺញ៉ុមឈប់ទៅ។

កៈ  ពូពេលហ្នឹងពូឈឺអីគេវិញ?

ខៈ   ពេលហ្នឹងញ៉ុមឈឺ ឈឺស្ងួត។

កៈ ហ្ញ៎។

ខៈ  ជំងឺស្ងួតហ្នឹង ។

កៈ  អាហ្នឹងហឺតហឺអីពូ?

ខៈ   ជំងឺស្ងួត។

កៈ  ស្ងួតយកតែម្ដងហោ?

ខៈ  បាទ!!

កៈ វាជាប់តាំងពីក្មេងមកឬក៏ទឹមតែមាន?

ខៈ   មានតាំងពីក្មេងមក។

កៈ ហ្ញ៎កើតមកអ៊ីចឹងមានស្រាប់ម៉ងពូណោះ?

ខ៖  បាទ!!

ក៖ វាម៉េចដែរពូអាហ្នឹងវាដង្ហក់ឬក៏ម៉េច?

ខ៖  ដង្ហក់។

ក៖  ម៉េចដែរក្ដៅម៉ងពូហោ?

ខ៖  បាទ!!

ក៖ ហាត់ម៉ង?

ខ៖បាទ!!

ក៖ ហ្ហ៎ពិបាកណាស់អ៊ីចឹងហ្ហ៎!!

ខ៖  តែឥឡូវញ៉ុមមើលជាហើយ។

ក៖ ហ្ហ៎ឥឡូវលែងអីហើយពូហោ?

ខ៖  បាទ!!

ក៖ តែឥឡូវអត់មានជក់បារីអីណាហី?

ខ៖  ជក់ដែរជក់ម្ដងៗ។

ក៖ ហ៊ីៗពូហាអាជំងឺសួតហ្នឹងតែជក់បារីពិបាកណាស់ !!

ខ៖  បាទ!!

ក៖ ធ្វើបាបតែខ្លួនឯងហ្នឹង។

ខ៖  ជួនកាលនេះជូរមាត់ជក់ទៅ។

ក៖ ចា៎!!

ខ៖  ហូបទៅ!!

កៈ ជូរមាត់ទិញស្ករគ្រាប់ហូបទៅ ផ្អែមៗអាហ្នឹងលែងអីវិញហាំ!!ដាក់អាហ្នឹងធ្វើបាបខ្លួនឯង។

ខៈ  ស្ករគ្រាប់ហូបខ្លាចពុកធ្មេញ។

កៈ  ហ៊ី!!អត់អីទេ មិនមែនដូចក្មេងៗទេ។

ខៈ   ស្ករគ្រាប់ធ្វើអោយពុកធ្មេញហើយ។

កៈ ជក់បារីអត់អីវិញអញ្ចឹងហេ??អូខេលោកពូរៀនបានថ្នាក់ទី២លោកពូណោះ?

ខៈ  បាទ!!

កៈ រៀននៅសាលាណាវិញ?

ខៈ   សាលានៅវត្តល្វា នៅខាងកំពង់ស្ពឺ។

កៈ  ទៅម៉េចទៅកំពង់ស្ពឺវិញ?

ខៈ  ព្រោះអីកាលហ្នឹងយើងរៀននៅនេះយើងវាឆ្ងាយ។

កៈ ហ្វាំ!!

ខៈ  បើយើងនៅខាងកំពង់ស្ពឺវាជិត។

កៈ ហា!ម៉េចទៅអញ្ចឹងវិញដោយសារស្រុកភូមិឆ្ងាយហេ?

ខៈ  បើរៀននេះនៅនេះគេមិនទាន់កសាងសាលានោះ។

កៈ ចាំ!!

ខៈ  ហើយកាលញ៉ុមនៅរៀនហ្នឹងវាជិត ។

កៈ  ជិតជាងវិញ?

ខៈ  បាទ!!

កៈ ប៉ុន្តែដើរមកពីផ្ទះវិញម៉ងអិចឹង?

ខ៖  បាទ!!

(មិត្តភក្តិ)៖អូននិយាយដើមរកាហ្នឹងខេត្តអី?

ខ៖   ខេត្តហ្នឹង ខេត្តតាកែវ។

ក៖  ហាដើមរកាខេត្តតាកែវវិញ?តែពូនៅស្រុកកណ្តាលស្ទឹង?

ខ៖  បាទ!!

ក៖ ស្រុកកណ្តាលស្ទឹងនៅខេត្តកណ្តាលតើ!!

ខ៖  ខេត្តកណ្តាលគ្រាន់តែជិតគ្នា!!

ក៖ ហ្ន៎!!

ខ៖  ព្រំប្រទល់ ព្រំប្រទល់ជាប់គ្នា ព្រំប្រទល់បីជាប់គ្នា។

ក៖ ហ្ន៎អីគេខ្លះពូ?

ខ៖   ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ។

ក៖ ហ្ន៎នៅជិតៗគ្នាហ្នឹងហី?

ខ៖  បាទ!!

ក៖ ឆ្លងមួយថ្នល់មួយថ្នល់ហ្នឹងហី?

ខ៖   ឆ្លងតែបន្តិចៗហ្នឹង។

ក៖ ហ្ន៎ហ្នឹងហើយពូថាទៅរៀននៅកំពង់ស្ពឺ!!

ខ៖  បាទ!!

ក៖ ដោយសារវានៅជិតហ្នឹង!!

ខ៖  ឆ្លងផ្លូវជាតិលេខ៣ហ្នឹង !!តើហ្ន៎!!

ខ៖  ឆ្លងផ្លូវជាតិលេខ៣ទៅលិចទៅ!!

ក៖ ដល់!!

ខ៖  បាទដល់សាលារៀនបាត់ហើយ!!

ក៖ ហ្នំគេហៅសាលាអីគេវិញពូគេហៅសាលាអីគេ?

ខ៖  សាលា។

ក៖ អីគេមិញល្វាវិញពូ?ពូរៀននោះ?

ខ៖  សាលាវត្តកំពង់ស្ដីសាលារៀនវត្តល្វាកំពង់ស្ដី។

ក៖ វត្តល្វាកំពង់ស្ដីហ្នឹងហោ?

ខ៖បាទ!!

ក៖ ពូទៅរៀននៅសាលាហ្នឹង?

ខ៖  បាទ!!

ក៖ ពូរៀនម៉េចដែរពូរៀនគ្រាន់បើទេ បើមុនឈឺរៀនបានច្រើនអីអត់?

ខ៖   ហ៊ីរៀនអត់បានចប់ផងនិយាយអោយចំម៉ងទៅ!!

ក៖ ចាំ!!

ខ៖  ញ៉ុមចេះតែឈឺពេកឈប់ទៅ។

ក៖ ក៏រៀនបានដល់ថ្នាក់ទី២!!

ខ៖  បាទ!!

ក៖ ក៏ឈឺទៅ?

ខ៖  បាទ!!

ក៖ ពេលហ្នឹងបែកពីសង្គ្រាមហើយពូណោះ?

ខ៖ បាទ!!

ក៖
អ៊ីចឹងពូសំរាប់មនុស្សម្នាក់ៗហាំតែងតែមានក្តីស្រម៉ៃរៀងៗខ្លួនហើយនៅពីក្មេងទោះថាមិនបាន
រៀនអីក៏ដោយ ពូពីក្មេងមកស្រម៉ៃចង់ធ្វើអីគេដែរ?

ខ៖ អត់ អត់មានស្រម៉ៃចង់ធ្វើអីផង ។

ក៖ អត់ដែលធំឡើងគិតថាចង់ធ្វើជាវិស្វករឬក៏មេសំនង់អីទេហេ?

ខ៖ ចុះបើយើងអត់ចេះអក្សរ ណាលោរប្រាថ្នាអត់កើត។

ក៖
តែដល់ពេលអញ្ចេកដល់ពេលថាទោះថាបើថាធំឡើងចង់រកស៊ីអីគេមួយអោយធំដុំអីអញ្ចឹងហាំ
??

ខ៖ ចង់ដែរសព្វថ្ងៃរកស៊ីលក់ដូរអីអញ្ចឹងទៅ!!

ក៖ ចាំ!!

ខ៖ បាទ!!

ក៖ តែពីក្មេងមកអត់ធ្លាប់គិតអីទេហេ?

ខ៖ អត់សូវទេ ចង់រកមានដើមអីចង់ទិញលក់ទឹកអំពៅឬក៏លក់ប្រហិតអីអញ្ចឹងទៅ!!

ក៖ ហ្នំ!!

ខ៖ បាទ!!

ក៖ ចាំអញ្ចឹងលោកពូពេលនៅកំពុងសិក្សារហ្នឹងមានមិត្តភក្តិជិតស្និតអីអត់?

ខ៖ មាន។

កៈ  គាត់ឈ្មោះអីគេដែរ?

ខៈ  ឈ្មោះម៉ៅ។

កៈ ឈ្មោះម៉ៅ?

ខៈ  បាទ!!

កៈ នៅរាប់អានគ្នាទល់ឥឡូវឬក៏ម៉េចដែរពូ?

ខៈ   នៅសព្វថ្ងៃហហ្នឹង។

កៈ ហ្ហ៎!!

ខៈ   នៅកំពង់ស្ពឺ។

កៈ គាត់នៅកំពង់ស្ពឺ?

ខៈ  បាទ!!

កៈ ហើយពូនៅខេត្តកណ្តាល!!

ខៈ  បាទ!!

កៈ តែវាជិតគ្នាទេ!!

ខៈ  ដើរទៅដល់។

កៈ ដើរដល់អញ្ចឹងពូ?

ខៈ  បាទ!!

កៈ លោកពូនៅពីក្មេងមកចូលចិត្តលេងអីគេខ្លះជាមួយពួកម៉ាក់ពូដែរ?

ខៈ   មានអី មានតែដើរលេងទៅមើលគេរាំវង់រាំអីអ៊ិចឹងទៅ។

កៈ ហ្ហ៎ អត់មានដើរវ៉ៃតាមភូមិអោយផ្អើលអីណាហី?

ខ៖  អត់ទេ!អត់ទេៗៗ

ក៖ ដោយសារភាគច្រើន!!

ខ៖  ទៅភូមិណាមានតែគេធ្វើមាន់អោយហូបវិញ!!

ក៖ ហ្វូ!!

ខ៖  ចាប់បាញ់ឆេវ តាមភូមិគេធ្វើមាន់ឬមួយក៏ចាក់បាញ់ឆេវអោយហូប។

ក៖  ចាំដោយសារមានមិត្តភក្តិនៅហ្នឹងឬក៏ម៉េចពូបានគេធ្វើអីអោយហូបអញ្ចឹង?

ខ៖  ទៅយូរៗស្គាល់អីអ៊ិចឹងទៅ!!

ក៖ ហ្វូ!!!

ខ៖  បាទ!!

ក៖ អ៊ីចឹងគេទទួលរាក់ទាក់អ៊ិចឹងទៅពូណោះ?

ខ៖  បាទ!!ទៅភូមិណាគេធ្វើបាញ់ឆេវហើ
ធ្វើមាន់បបរអីអ៊ិចឹងទៅបបរអីអោយហូបអ៊ីចឹងណាស់!!ក៖ ចាំ!!

ខ៖  ជូនកាលបបរមាន់ ជូនកាលបបរស្ករអីអ៊ីចឹងទៅ!

ក៖ ចាំ!!

ខ៖  ធ្វើអោយហូបទៅ។

ក៖ តែពូម៉ៅហ្នឹងគាត់ឈប់រៀនដំណាលពូឬក៏គាត់នៅតទៅទៀត?

ខ៖  គេរៀនបានច្រើនជាងញ៉ុម។

ក៖ ចាំ!!

ខ៖  គេ!!

កៈ អត់បានបញ្ឈប់ដូចពូព្រោះគេសុខភាពល្អអញ្ចឹងទៅហេ??

ខៈ បាទ!!

កៈ ដោយសារពូជំងឺសួតអិចឹងទៅ!!

ខៈ បាទ!!

កៈ ក៏ឈប់អញ្ចឹងៅទៅ?

ខៈ បាទ!!

កៈ ពេលហ្នឹងធ្ងន់ធ្ងរមែនពូបានអញ្ចឹង?

ខៈ បាទ!!!

កៈ ទៅរៀន ប៉ុន្តែពូជំងឺសួតហ្នឹងពូមានដែលសន្លប់មានដែលអីអត់?អត់ណាហី?

ខៈ ដែល។

កៈ ដល់ថ្នាក់សន្លប់អីវ៉ាន់ទៀត?

ខៈ បាទ!!

កៈ វាម៉េចបានវាដល់ថ្នាក់ទៅដល់សន្លប់អញ្ចឹងពូ?

ខៈ យើងដូចថា ក្តៅ ក្តៅពេកយើងសន្លប់អញ្ចឹងទៅ?

កៈ ថប់ដង្ហើមអីចឹងម៉ង?

ខៈ បានទថប់ៗ។

កៈ ហើយអត់ដឹងខ្លួនហេពូពេលហ្នឹងហេ?

ខៈ អត់។

កៈ ដូចដេកលក់អញ្ចឹងពូហេ?

ខ៖  បាទ!!ដូច!!

ក៖ ដូចក្នុងយល់សប្តិមួយអីអញ្ចឹងហោ?

ខ៖  បាទ!!

ក៖ ចាំ!!

ខ៖  ដូចយើងសំរានលក់អញ្ចឹង!!

ក៖
ចាំ!!អញ្ចឹងលោកពូសំរាប់តែដល់ពេលបានរៀនដល់ទី២អញ្ចឹងក៏បានរៀនចេះអានអីដែរពូណោះ?

ខ៖  ភ្លេចអស់ហើយឥឡូវ។

ក៖  តែពេលហ្នឹងនៅចេះអានចេះសរសេរទេអញ្ចឹង?

ខ៖   ចេះតែឥឡូភ្លេចអស់មិនសរសេរម៉េចៗអត់!!

ក៖ ដោយសារអត់រំលឹកអញ្ចឹងពូហោ?

ខ៖  បាទ!!

ក៖ ពូចូលដល់នេះវិញម្តង ចូលដល់ប្រពន្ធពូរៀបការប្រពន្ធគាត់ឈ្មោះអីគេដែរ?

ខ៖   ប្រពន្ធមុនឬក៏ប្រពន្ធក្រោយ?

ក៖  ប្រពន្ធ២អីចឹងណោះ?ឥឡូវនិយាយពីប្រពន្ធមុនសិន !!ប្រពន្ធមុនគាត់ឈ្មោះអីគេពូ?

ខ៖   ឈ្មោះខុម។

ក៖  អីគេខុម?

ខ៖   ជុក ជុក ខុម។

ក៖ ជុក ខុម?

ខ៖ បាទ!!

ក៖ ពូរៀបការជាមួយអ្នកមីងខុមនៅឆ្នាំណាវិញពូចាំទេ?

ខ៖ អត់អត់ចាំ។

ក៖ ពូអាយុប៉ុន្មានពូរៀបការ?

ខ៖ ញ៉ុមអាយុ២០ជាង ២២។

ក៖ ២២បានរៀបការហោ?

ខ៖ បាទ!!!

ក៖ អ៊ិចឹងពូរៀបការ២០ឆ្នាំមុន?

ខ៖ បាទ!!

ក៖ អញ្ចឹង១៩៩៨។

ខ៖ បាទ!!

ក៖ អញ្ចឹងពូការពេលហ្នឹងហើយបើដកតាមហ្នឹងទៅ!!ពូជួបមីងដំបូងនៅណាវិញ?

ខ៖ បាទ?

ក៖ ជួបពេលណាដំបូងប្រពន្ធហាំ??

ខ៖ ប្រពន្ធមុនដំបូងនៅភូមិហ្នឹងដែរ។

ក៖ នៅភូមិហ្នឹងដែរហោ?

ខ៖ បាទ!!

ក៖ ស្រលាញ់គ្នាដោយចិត្តឯងឬក៏ឪពុកម្តាយរៀបចំការអីអោយ?

ខ៖ ស្រលញ់គ្នាខ្លួនឯង។

កៈ  ហើយបានរៀបការអ៊ីចឹងទៅ?

ខៈ   បាទ!!

កៈ  ចាំរៀបការហ្នឹងគេមានទារជំនូនអីអត់ពូ?

ខៈ   ជំនូនដែរហ្នឹង គេមានហែរជំនូនដែរហ្នឹង។

កៈ ចាំ!!!អ៊ិចឹងការដូចគេឥឡូវហ្នឹងដែរពូណេះ?

ខៈ   បាទ!!

កៈ  ហ៊ីធំដុំដែរតើអញ្ចឹងហោ?

ខៈ  ធំដុំដែរ!!

កៈ  ពូអោយជំនូនជាអីគេវិញ?

ខៈ   ជាផ្លែឈើជាអី!!

កៈ អាហ្នឹងដឹងថាជំនូនហើយ តែអាថ្លៃជំនូនថ្លៃទឹកដោះអីវ៉ាន់អីនោះហ្នូ លុយមាស??

ខៈ   ហ្នូ!!អាហ្នឹងអោយអីគេគេវិញ?អាហ្នឹងអោយលុយ!!

កៈ ប៉ុន្មានដែរពូជំនាន់ហ្នឹងពូ?

ខៈ   ១០០០០០០។

កៈ  ២៥០(ដុល្លារ)?

ខៈ  បាទ!!តែកាលជំនាន់ហ្នឹងគេយក១០០០០០០រៀល។

កៈ ចាំគេគិតលុយខ្មែរ !!

ខៈ  បាទ!!

កៈ ឥឡូវសុទ្ធតែពាន់ដុល្លារ។

ខ៖  ណោះ១២០០(ដុល្លារ)។

ក៖ ឥឡូវនិយាយពីប្រពន្ធមុនអោយអស់សិនចាំដល់ប្រពន្ធក្រោយ
អញ្ចឹងលោកពូពេលរៀបការបានប៉ុន្មានឆ្នាំបានលែងគ្នា?

ខ៖  បានកូន២។

ក៖ បានកូនអាយុប៉ុន្មានឆ្នាំទៅបានអញ្ចឹង បានបានកូន២?

ខ៖ ហ៊ឺ!ជាង១០ឆ្នាំ!!

ក៖ ហ្ហ៎យូរដែរហោ??

ខ៖ បាទ!!

ក៖ ហើយតែឥឡូវគាត់ចាកចេញពីពូហើយ?

ខ៖ បាទ!!

ក៖ ហើយមានលែងលះគ្នាអីត្រឹមត្រូវអីអត់?

ខ៖  ត្រឹមត្រូវតើ ទៅដល់ឃុំ!!

ក៖ ហ្ហ៎!!ហើយដល់ពេលសួរមូលហេតុអីទៅមុលហេតុអីគេដែលលគាត់អ៊ីចឹង?

ខ៖  អត់មានមូលហេតុអីទេគ្រាន់តែយើងមូលហេតុថាដូចលេងប៉ែឡុកប៉ែឡរអ៊ិចឹង។

ក៖ លេងប៉ែឡុកប៉ែឡរម៉េចពូជីវិតហា៎??

ខ៖  យើងជីវិតគ្រាន់តែថា យើងវ៉ៃក៏អត់វ៉ៃ ជេរប្រចោរក៏អត់ជេរប្រចោរ ដូចយើងរៀងៗខ្លួន
ដូចថាអស់រៀងៗខ្លួន ដូចថាអស់និស្ស័យគ្នាអីអញ្ចឹងទៅ!!

ក៖  ហ៊ឺអ៊ីចឹងទៀត តែកូននេះត្រូវគិតពីកូននេះ!!

ខ៖  តែកូនវាអត់មកតាមយើងទេ តែគ្រាន់តែនៅផ្ទះជិតគ្នា
ពេលមកអញ្ចឹងទៅថាកូនហ្នឹងទៅញ៉ូមអោយឧស្សាហ៍ទៅលេងផ្ទះហ្នឹងអោយទៅអត់ទៅទេ។

ក៖ ចាំ!!

ខ៖ បាទ!!

ក៖ តែគ្រាន់តែថាមកលេងពូលេងអីអញ្ចឹងដែរ?

ខ៖ បាទ!!

ក៖ ហ៊ីតែកូន២ហ្នឹងនៅជាមួយពូឬក៏នៅជាមួយមីង?

ខ៖ នៅជាមួយគេ នៅជាមួយគេ។

ក៖ នៅខាងណោះវិញអញ្ចឹងហោ?

ខ៖ បាទ!!តែគ្រាន់តែថាផ្ទះនៅជិតគ្នា។

ក៖ ហ្អំ តែទៅលេងគ្នាទៅវិញទៅមកអញ្ចឹងទៅពូណោះ?

ខ៖ បាទ!!

ក៖ ដែលជួបមុខប្រពន្ធទេពេលលែងគ្នាហើយ?

ខ៖ ថីនឹងជួប។

ក៖ ជួបដែរហោ?

ខ៖ បាទ!!

ក៖ ហើយគាត់មានប្ដីនៅឥឡូវ?

ខ៖ ហ៊ីមានបីមុនញ៉ុមទៀតហ្អំ!!

ក៖ អូយ!!

ខ៖ គ្រាន់តែបែកពីញ៉ុមទៅមាន៣។

ក៖ ចំ អញ្ចឹងមិនមែនដោយសារគាត់មានប្រុសមានអីទេហោ?

ខ៖  គេ គេមានប្រុសមុនញ៉ុម។

ក៖  ហាពេលហ្នឹងនៅមានចំណងអាពាហ៍ពិពាហ៍នៅជាមួយគ្នាតែគាត់មានមុនពូ?

ខ៖   គេតែនិយាយគ្នាតាមទូរសព្ទ័!!

ក៖ ហ្ហ៎!!

ខ៖   គេស្គាល់គ្នា!!គេទៅណាត់គ្នាអីណានៅណាអីចឹងទៅណាស់!!

ក៖ ហ្ហ៎!!

ខ៖  បានបាន បែកបាក់គ្នាហ្នឹង។

ក៖ ចំ!!

ខ៖  បាទ!!

ក៖ អញ្ចឹងដោយសារអីចឹងទេអញ្ចឹង?

ខ៖  បាទ!!

ក៖ ហើយគេទៅស្រលាញ់ណោះអញ្ចឹងទៅបានអស់ចិត្តពីពូណោះអីចឹងទៅ?

ខ៖  បាទ!!!

ក៖ ហើ!!

ខ៖  គេទៅស្រលាញ់ណោះហើយបានគេយក ញ៉ុមដឹងញ៉ុមអញ្ចឹងទៅ។

ក៖ ក៏អោយទៅទៅ?

ខ៖  បាទ ក៏អោយចែកគ្នាតាមដំនើរអីចឹងម៉ងទៅ!!

ក៖ ពូ ខឹងទេពូពេលអញ្ចឹង លឺដំបូងម៉េចដែរ?

ខ៖   ហ៊ីខឹងដែរប៉ុន្តែគ្រាន់តែថាមិនដឹងធ្វើម៉េចយើងទៅរ៉ែថប់គេម៉េច!!

ក៖  ចាំ!!ធម្មតាឮតែប្រុសៗធ្វើអញ្ចឹងដល់ពេលឮស្រីៗហោ!!

ខ៖  បាទ!!

ក៖ សាហាវដែរហ្នឹងមីងហា?ពូចាំអនុស្សាវរីយ៍ ដូចជាចាប់ផ្ដើមស្នេហាដំបូងជាមួយអ្នកមីង មុនដំបូងម៉េចដែរបានស្រលាញ់គ្នា?

ខ៖  យើងនិយាយធម្មតា និយាយថាអីអញ្ចឹងទៅ!!

ក៖ អីអញ្ចឹងទៅម៉េចទៅពូ!!

ខ៖   និយាយថាចែងឯងធ្វើអិធ្វើអីអញ្ចឹងទៅណាស់!!

ក៖ ចាំ!!តែស្គាល់គ្នាពីក្មេងមកទេ?

ខ៖   ស្គាល់តើ!!តាំងពីក្មេងមក។

ក៖  ហ្ហ៎អញ្ចឹងអ្នកភូមិឃុំជាមួយគ្នាអីចឹងទេពូណោះ?

ខ៖  បាទ!!

ក៖ ផ្ទះជិតគ្នាប្រវែងៗម៉ានទៅពូជីតដែរហេ?

ខ៖   ផ្ទះហ្នឹង នៅអញ្ចេះឈៀកអញ្ចេក។

ក៖ ហ្ហ៎!!

ខ៖  មុនដំបូងគេនៅស្រុកសៀមរាបណោះហ្នឹងតែគេទឹមមកនៅទឹមមកយកបងប្អូនហាំ!!

ក៖ ចាំ!!

ខ៖  ដល់ហើយទៅបានស្គាល់ហើយស្រលាញ់គ្នាអីចឹងទៅ។

ក៖  ហ្ហ៎ តែពេលហ្នឹងគាត់មកនៅក្មេងៗឬក៏គាត់ធំហើយបានមកនៅមក?

ខ៖   ក្រមុំហើយហ្នឹង។

កៈ ហ្ហ៎អញ្ចឹងមិនមែនស្គាល់គ្នាតាំងពីក្មេងៗទេ!!

ខៈ  គាត់ក្រមុំហើយធំហើយ។

កៈ ឃើញទៅពូក៏ចាប់ផ្ដើមញ៉ែអ៊ីចឹងទៅពូណោះ?

ខៈ ហ្នឹងហើយ។

កៈ
អ៊ីយ៉ាស់!!ចា៎!!អញ្ចឹងពូឥឡូវបែកគ្នាពីប្រពន្ធទីមួយហើយដោយសារប្រពន្ធរបស់លោកពូគាត់ទៅលួចទៅមានស្វាមីផ្សេងទៀត។

ខៈ មានប្រុសទៀត!!

កៈ ប៉ុន្មានឆ្នាំទៀតបានពូរៀបការបែកពីមីងមក?

ខៈ ញ៉ុម៦ ៧ឆ្នាំ។

កៈ ហ៊ុយូរដែរហ្នឹងអ៊ីចឹង។

ខៈ បាទ!!

កៈ ពូឈឺចិត្តទេ ឈឺខ្លាំងទេ?

ខៈ អត់ធម្មតា។

កៈ ហ៊ីញ៉ុមមិនជឿទេថាធម្មតាហ្ហ៎!!

ខៈ ធម្មតាមែន!!

កៈ ហ៊ឺ!!

ខៈ បែកពីគេញ៉ុមដើរលែងមួយឆ្អែត ។

កៈ បានយកប្រពន្ធហោ?

ខៈ បាទ!!

ក៖ ហើយចុះកូនអីវ៉ាន់អត់សូវខ្វល់ដែរណាពូហី?

ខ៖  កូនធម្មតា។

ក៖ តែរកបានអោយគាត់អីវ៉ាន់ចាយអញ្ចឹងទៅពូណោះ?

ខ៖  បាទ!!

ក៖  ចាំពូប្រពន្ធក្រោយគាត់ឈ្មោះអីគេវិញអ្នកមីង?

ខ៖   ឈ្មោះជុក ថេង។

ក៖  ជុក ធី?

ខ៖  ហាជុក ថេង!!!

ក៖ ហ៊ីអត់ចាំប្រពន្ធខ្លួនឯងឥឡូវម៉េចទីពូ?

ខ៖   ឈ្មោះអីគេទេឪគេ!!ប្រពន្ធស្គាល់តែភ្លេចឪ!!ឈ្មោះចឹក ចឹក ថេង។

ក៖  ចឹង ថេង?

ខ៖  បាទ!!

ក៖ ចាំ!!អ្នកមីងគាត់ឥឡូវអាយុប៉ុន្មានហើយ?

ខ៖   ៥៦

ក៖ ៥៦ អ៊ីចឹងបងលោកពូវិញ?

ខ៖  បាទ!!

ក៖ ចាំឥឡូវគាត់រស់នៅឯណាវិញ?

ខ៖   នៅព្រែកហូរ។

ក៖  ជួលផ្ទះគេនៅហោពូ?

ខ៖  ផ្ទះរបស់ខ្លួនឯង។

ក៖  ហ្នំអញ្ចឹងលោកពូមានផ្ទះរបស់ខ្លួនឯងហោ?

ខ៖  ផ្ទះម្ដាយហ្នឹងហាំ!!

ក៖ ចាំ!!

ខ៖  ហើយផ្ទះហ្នឹងដូចថាយើងចេញលុយអោយប្អូនអោយ១០០០
តែឥឡូវអត់ទាន់បានលុយអោយប្អូនទេ!!

ក៖ ចាំ!!

ខ៖  ផ្ទះហ្នឹង។

ក៖ ហើយប៉ុន្មានពាន់ពូ?

ខ៖  ផ្ទេរអោយ១០០០។

ក៖ ហ្នំអត់សូវច្រើនប៉ុន្មានដែរហ្នឹងអញ្ចឹង?

ខ៖  បាទ!ផ្ទះយើងល្មមដែរអញ្ចឹង។

ក៖ លោកពូម៉េចវិញបានជួបនឹងអ្នកមីងក្រោយវិញ?គាត់មេម៉ាយឬក៏ក្រមុំ?

ខ៖  ក្រមុំចាស់។

ក៖ ក្រមុំចាស់ហោ?

ខ៖  បាទ!!

ក៖ ហើយម៉េចបានមកជួបគ្នា?

ខ៖  គេកាត់ស្មៅ ដូចថាគេថ្ងៃ ថ្ងៃអាទិត្យទៅគេធ្វើហើយក៏ជួបគ្នាទៅ!!

ក៖ ហ្នំទៅកាត់ស្មៅនៅឯណាវិញ?

ខ៖  កាត់យើងនៅស្រែអំពិលហ្នុ៎!!កៀនស្វាយកៀនអីហ្នឹង។

ក៖ ហ្នុ៎!!

ខ៖  ជិះឡានទៅ។

ក៖  កាត់ស្មៅអីគេវិញពូបានទៅកាត់ស្មៅវិញ?ច្រូតស្មៅឬក៏ម៉េច?

ខ៖   ច្រូតស្មៅ។

ក៖  ច្រូតស្មៅលក់ហោ?

ខ៖   បាទ!!

ក៖ ហ្នុ៎អ៊ីចឹងបានជួបគ្នា។

ខ៖  យើងយកទៅបោះអោយឡានគេហ៎!!

ក៖ ចាំ!!

ខ៖  យើងទៅជាមួយឡានគេហ្នឹង។

ក៖ ហ្នុ៎ហើយអញ្ចឹងក៏បានជួបគ្នាម៉ងទៅ?

ខ៖  បាទ!!

ក៖ ហើយក៏មានទំនាក់ទំនងគ្នា !!រៀបការដែរពូហោ?

ខ៖   រៀប។

ក៖ រៀប ឬក៏រៀបការ?

ខ៖   រៀបការ។

ក៖ រៀបការអីដូចមានភ្លេងមានអីត្រឹមត្រូវអីវ៉ាន់អញ្ចឹងទៅពូណោះ?

ខ៖  បាទ!!

ក៖ ប៉ុន្មានឆ្នាំហើយរៀបការជាមួយមីង?

ខ៖ ២ឆ្នាំហើយ បានមកសព្វថ្ងៃបានមកពីរឆ្នាំហើយ!!

ក៖ ហើយទឹមតែបានពីរឆ្នាំទេចុះ?

ខ៖ បាទ!!

ក៖ ហ៊ឺ!!!ពូបានរៀបការពីរដង ហោតែអត់ចង់បានទេយកតែម្តងៗបានហើយ!!

ខ៖ បាទ!

ក៖
តែមិនដឹងធ្វើម៉េចដោយសារនិស្ស័យជាមួយប្រពន្ធត្រូវបានអស់ដោយសារមីងគាត់អញ្ចឹងទៅណោះទៅណោះពូ?

ខ៖ បាទបាទ!!

ក៖ ចាំ!!

ខ៖
ចាំអញ្ចឹងលោកពូអ្នកមីងស្រលាញ់គ្នាសិនបានម៉ែឪចូលស្តីបានពូអោយគាត់ចូលស្តីខាងស្រីអីវ៉ាន់អញ្ចឹងទៅពូណោះ?

ខ៖ បាទ!!

ក៖ ក៏ស្រលាញ់គ្នា។

ខ៖ បានអោយមមកនិយាយ។

ក៖ ចាំពូប្រពន្ធក្រោយមានកូនប៉ុន្មានហើយ?

ខ៖ អត់ អត់មានផង!!

ក៖ អត់ទាន់មានកូនទេអីចឹង?

ខ៖  បាទ!!

ក៖ ហ៊ីអញ្ចឹងចុះបើយកកូនមុនមកនៅជាមួយមកមានថី?

ខ៖  គេអត់អោយយើងមក។

ក៖ អ្នកខាងប្រពន្ធនោះទេហេ?

ខ៖  បាទ!!

ក៖ មិនព្រមចែកគ្នាមួយទៅដោយសារនៅណោះមានដល់ទៅពីរហើយហ្នឹង។

ខ៖  បើវាអត់មកអត់មកតាម។

ក៖ ហ្ហ៎!!

ខ៖  បើវាអត់មានយើងក៏ខ្ជិលបំបែកវាដែរ។

ក៖ ចាំបើគ្នាមិនចង់ហើយពូណោះ?

ខ៖  បាទ!!

ក៖ អញ្ចឹងលោកពូអ៊ីចឹងកូនទាំងអស់មានតែ២នាក់ទេឥលូវហ្នឹងនោះ?

ខ៖  បាទ!!

ក៖ ព្រោះដោយសារអ្នកមីងគាត់អត់ទាន់មានកូនទេ។

ខ៖  បាទ!!

ក៖ អញ្ចឹងសំរាប់កូនពូគាត់ឈ្មោះអីគេខ្លះ?

ខ៖  ឈ្មោះ នៅហើយនឹងឈ្មោះ ណេត។

ក៖  ណេត!!

ខ៖  បាទ!!

ក៖ ស្រីទាំង២ឬក៏ប្រុសទាំងពីរ?

ខ៖  ប្រុសទាំងពីរ។

ក៖ ត្រកូលឱនដែរហោ?

ខ៖ ត្រកូលញ៉ុមហ្នឹង។

ក៖ ត្រកូលជឿន?

ខ៖ បាទ!!

ក៖ ជឿន ណេត ជឿន នៅ?

ខ៖ បាទ!!

ក៖ អីយ៉ាស់ អត់មានដាក់អីផ្សេងទៀតទេពូហោ?

ខ៖  អត់។

ក៖
អ៊ីចឹងពូសំរាប់ប្រពន្ធលោកពូគាត់ជាមនុស្សចរិកម៉េចដែរប្រពន្ធក្រោយអត់អីណាហីអត់ដូចមុនណាហី?

ខ៖ អត់អីទេ។

ក៖ គាត់សុភាពរម្យទុំអីអញ្ចឹងទៅហី?

ខ៖ បាទ!!

ក៖ ឥឡូវអ្នកមីងអាយុ៨៦ឆ្នាំហើយ?

ខ៖ បាទ!!

ក៖ អ្នកមីងអ្នកស្រុកកើតនៅឯណាវិញ?

ខ៖  នៅមុនដំបូងនៅស្អាង ។

ក៖ ចាំ!!

ខ៖ ដល់ឥឡូវយើងមកនៅមកទិញដីនៅព្រែកហូរហ្នឹង។

ក៖ ចាំអញ្ចឹងក៏រស់នៅហ្នឹងម៉ងទៅពូណោះ?

ខ៖ បាទ!!មកនៅហ្នឹង១០ឆ្នាំហើយ!!

ក៖ ចាំ!!

ខ៖ បាទ!!

ក៖ យូរណាស់ហើយអញ្ចឹងហ្ន៎!!

ខ៖ បាទ!!

ក៖ អញ្ចឹងលោកពូ សំរាប់លោកពូមានអោយកូនទៅរៀនទេ
កូនទាំងពីរនាក់នោះហាំ!!គាត់បានអោយទៅរៀនទេ?

ខ៖ រៀន អាប្អូនកំពុងតែរៀនបើអាបងឈប់ហើយ វាមានប្រពន្ធហើយ។

ក៖ ហា!!ហើយអញ្ចឹងមានកូនប្រសារហើយអញ្ចឹង?

ខ៖ បានមានហើយមានចៅហើយ ចៅពីរហើយ!!

ក៖ ហាំ!!អីចឹងពូទំរាំតែបានមកជួបនឹងអ្នកមីងយូរដែរហ្នឹងអីចឹងហោ?

ខ៖ បាទ!!

ក៖ ហើយតែមានចៅហើយកូនការហើយបានមកជួបប្រពន្ធក្រោយហោ?

ខ៖ បាទ!!

ក៖ អញ្ចឹងការក្រោយកូនទេហោ?

ខ៖ ការក្រោយកូន។

កៈ អីយ៉ាស់!!កូនអាយុប៉ុន្មានបានមានប្រពន្ធហើយពូ?

ខៈ  អាយុវាបន្តិចហ្នឹងជាង១០ឆ្នាំហ្នឹង។

កៈ  ប៉ុន្មាន១០ឆ្នាំហ្នឹង?

ខៈ  ១២ឆ្នាំហ្នឹង។

កៈ  ពូបោកសុទ្ធ?

ខៈ   បោកម៉េចបើ១២ឆ្នាំវាមាន ចុះបើគេស្រលាញ់គ្នាហើយយើងការអោយវាទៅ!!

កៈ អាណាគេកូន១២ឆ្នាំអោយការម៉េចទេពូ?

ខៈ  កូនញ៉ុមទំលោកហា៎ ប៉ុណ្ណាប៉ុនណឹហើយ!!

កៈ ដោយសារទំលោកមានប្រពន្ធមានអីហើយអញ្ចឹង?

ខៈ  បាទ!!

កៈ ១២ឆ្នាំរៀបការ?

ខៈ  បាទ!!

កៈ ញ៉ុមទឹមតែឮទេនេះលោកចង់ធ្លាក់ថ្លើមងាប់ហើយនេះ!!

ខៈ  វា១២ឆ្នាំវាធំ កូនញ៉ុមធំសឹងតែជាងធំជាងញ៉ុមទៅទៀតណោះ!!!

កៈ ចំ ចុះត្រលោកអីត្រលោកខ្លាំងម្លឹងៗ!!

ខៈ  បាទ!!

កៈ ចុះអាប្អូនប៉ុន្មាន?

ខៈ   អាប្អូនទឹមប៉ុន្មានទឹមជាង៥ឆ្នាំហ្នឹង!!

កៈ ហ៊ី!!លោក អូយលោកអើយលោក!!

ខ៖  ហើយម៉េចធ្វើម៉េចបើវាស្រលាញ់គ្នាវាហើយ។

ក៖ ហើយចុះឥឡូវគាត់អាយុប៉ុន្មានហើយ?

ខ៖   ដូចជា១០ឆ្នាំហ្នឹង។

ក៖  ១២ឆ្នាំដដែល តែឥឡូវហាំ?

ខ៖   តែឥឡូវវាឡើង១៩ហើយ!!

ក៖ ហើយមានកូន១៩ឆ្នាំ?

ខ៖  មានកូន២នាក់។

ក៖  ១៩ឆ្នាំឥឡូវមានកូន២?

ខ៖  បាទ!!

ក៖ ញ៉ុមអត់ដែលឃើញទេនេះហ៎!!ទឹមតែលឺមួយហ្នឹងទេហ៎!!

ខ៖  បាទ!!

ក៖ ហើយអ៊ីចឹងប្រពន្ធអាយុប៉ុន្មានហើយប្រពន្ធ?កូនប្រសារពូ?

ខ៖   កូនប្រសារអោយុជាង១៨ឆ្នាំ អាយុ១៨ឆ្នាំ។

ក៖ ហាអ៊ិចឹងបងរបស់!!

ខ៖   បងរបស់ប្តី។

ក៖  គ្រាន់បើតិចអ៊ីចឹង
បើណេះ១២ឆ្នំានោះ១៩ឆ្នាំទៀតងាប់បណ្តោយ!ហើយចេះតែម៉ែឪខាងស្រីនោះក៏អោយទៀត?

ខ៖  ហ្នឹង!!

ក៖ ហើយរកស៊ីអីគេកូនពូចិញ្ចឹមប្រពន្ធ?

ខ៖  ធ្វើសំនង់។

ក៖ អូយងាប់ហើយនៅណាឥឡូវហ្នឹង?

ខ៖   នៅស្រុកហ្នឹង!!

ក៖ នៅស្រុកធ្វើសំនង់នៅហ្នឹងដែរ?

ខ៖  បាទ!!

ក៖ អើយពូអើយពូញ៉ុមចង់ធ្លាក់ថ្លើមម៉េចទៅពូនេះ!!ឮ១២ឆ្នាំការអញ្ជឹងអត់ដែលឮហ្នំ!!អូខេពូមូលហេតុអីបានពូអោយកូនទៅសិក្សាដែរពូមានបានផ្តល់លុយទៅអោយគាត់ទៅសិក្សាទៅអីអីអត់?

ខ៖  ផ្តល់។

ក៖ មូលហេតុអីបានជាពូផ្តល់ហើយមូលហេតុអីបានពូបញ្ជូនកូនអោយទៅរៀនហ្នឹងហាំ??

ខ៖  រៀនហ្នឹងអោយវាមួយព្រឹក១០០០ ២០០០អីអញ្ជឹងទៅ!!

ក៖ ចាំ!!

ខ៖
ហើយមូលហេតុអីបានពូគិតថាការសិក្សាវាសំខាន់សំរាប់ពួកគាត់អីចឹងទៅណាស់?អោយវារៀនសូត្រអោយវាបានចំនេះអោយវាបានទៅមុខទៀត។

ក៖ ចាំកុំអោយពិបាកអត់ចេះអានចេះនេះអីអិចឹង!!

ខ៖   កុំអោយដូចខ្ញុំ។

ក៖ ចាំ!!

ខ៖  អោយបានចេះទៅវាស្រួល!

ក៖ ចាំ!!

ខ៖ ទៅណាទៅណីអីចឹងទៅ!!បាទ!!

ក៖ ហ្នឹងហើយៗពូឆាប់យកកូនដើម្បីអោយមានកូនទៀតនៅជាមួយពូ!!

ខ៖ បាទ!!

ក៖ ចាំអីចឹងពូចូលដល់ប្រវត្តិសង្គ្រាមហាំពូសំរាប់អើរ លោកពូកើតទាន់ទាំងជំនាន់លន់ នល់ ជំនាន់ប៉ុល ពតពូណោះ?

ខ៖ បាទ!!

ក៖ តែពូបានដឹងអីគេខ្លះពីជំនាន់លន់ នល់?

ខ៖ ហូបបបរ ហូបបបរលាយដើមចេក។

ក៖ និយាយថាលន់ នល់ហាំ លន់ នល់ អត់ទាន់ចូលដល់ប៉ុល ពតទេ!!មានដែលញ៉ុមឮភាគច្រើនញ៉ុមដូចឮពេលហ្នឹងគេមានទំលាក់គ្រាប់បែក។

ខ៖ ហ្នឹងហើយ!!ហ្នឹងទំលាក់គ្រាប់បែក។

ក៖ ម៉េចទៅ?ពូទាន់ឃើញអីឃើញអីទេ?

ខ៖ ទាន់។

ក៖ តែអាយុប៉ុន្មានពេលហ្នឹងជំនាន់លន់ នល់?

ខ៖ ញ៉ុមធំជាងហ្នឹងបន្តិច(ចង្អុលទៅក្មេងនៅក្បែរហ្នឹងអាយុ៣ឆ្នាំ)!!ក៖ ចាំ!!ខ៖ ប្រហែល៦ ៧ឆ្នាំ។

ក៖ លន់នល់ ៦ ៧ឆ្នាំហេ?

ខ៖ បាទ!!ធំដែរកាលហ្នឹង។

ក៖ តែឃើញគ្រាប់ឃើញអីដែរតើពូហេកាលហ្នឹង?

ខ៖ បាទឃើញគ្រាប់ធំៗតើប៉ុនៗៗដើមដូង ធំជាងដើមដូងទំលាក់មក!!

កៈ ហ្នំ ហើយពូឃើញឃើញងើយទំលាក់មកឃើញអញ្ចឹងម៉ងហោ?

ខៈ  ឃើញតើ ទំលាក់មក តែឥឡូវគេលុបអីអស់ហើយ!!នៅស្រុកញុំមហ្នឹង
រណ្ដៅប៉ុនៗណាណី រណ្ដៅអាបេ!!

កៈ អូយរណ្ដៅអាបេ?

ខៈ  បាទ!!

កៈ ពូ មើលពូដឹងអីគេខ្លះពីលន់ នល់ ពូនិយាយរៀបរាប់អោយអស់មើល?

ខៈ  ពីលន់ នល់ ស្អីគ្រាន់តែថាយើងរត់ដូចតែនេះយើងហ្នឹងដែរហ្នឹង!!

កៈ ហ៊ឺៗ!!

ខៈ រត់ចូលត្រង់សេត្រង់អីយើងហ្នឹង!!

កៈ ចាំ!!

ខៈ អាខ្លះគេហៅត្រង់សេ អាខ្លះគេហៅថារុនមនុស្ស។

កៈ រុនមនុស្ស។

ខៈ នៅត្រង់សេហ្នឹង។

កៈ ចាំ!!

ខៈ  ខួង ខួងត្រង់សេអញ្ចឹងទៅ!ណាស់!!

កៈ ចាំ!!

ខៈ យើងខួងចូលនៅហាំ!!

កៈ ហ្នំហើយដកដង្ហើមម៉េចទៅពូ?

ខៈ  អត់អីទេ យើងជីកក្នុងហ្នឹងធំទៅ ។

កៈ អត់ដែលបាក់ដីបាក់អីលើណាពូហី?

ខៈ  អត់ទេ!!

កៈ ហ៊ី!!

ខៈ   យើងជីកធ្វើកំពែងនៅក្នុងដំបូកហ្នឹងទៅ!!

កៈ ចាំ!!

ខៈ  បាទ!!

កៈ ហើយគេចផុតពីគ្រាប់ដែរតើពូណោះ?

ខៈ  រួច។

កៈ តែពូពេលជីកត្រង់សេហ្នឹងពេលហ្នឹងជីកនៅជិតផ្ទះឬក៏ទៅឯណាឆ្ងាយ?

ខៈ  វាលស្រែ។

កៈ វាលស្រែវិញ?

ខៈ  បាទវាលស្រែ!!

កៈ ហ្អុំ!!

ខៈ  យើងនៅក្នុងភូមិ ក្នុងភូមិយើងអត់មានទេមានតែតាមវាលស្រែហ្នឹងត្រង់សេហ្នឹង។

កៈ បើក្នុងភូមិវាឃើញផ្ទះដដែលវាទំលាក់។

ខៈ  បាទ!!យើងនៅក្នុងភូមិអត់កើតទេ យើងនៅបាននៅតែក្នុងតាមព្រៃអីទេ នៅក្នុងយើងត្រង់សេហ្នឹងទេ!!

កៈ ហ៊ីៗ!!

ខៈ  បើនៅក្នុងភូមិយើងនៅអត់កើត!!

កៈ ចាំ!!

ខៈ និយាយរួមទៅ។

កៈ ចាំ!!អញ្ចឹងបើនៅក្នុងភូមិគេទំលាក់គ្រាប់ត្រូវពូហោ?

ខៈ បាទ!!

កៈ ពូនៅក្នុងភូមិអីវ៉ាន់!!ដូច

ខៈ គេអត់អោយនៅក្នុងភូមិ។

កៈ គេជំលៀសចេញមកហោ?

ខៈ គេជំលៀសចេញមកអោយយើងនៅតាមវាលស្រែនៅតាមក្នុងត្រង់សេ។

កៈ ហ្នំមានផ្ទះមានអីឆេះដែរពូអត់ ត្រូវគ្រាប់អីវ៉ាន់អញ្ចឹងណាស់?

ខៈ មានផ្ទះមានអីឆេះដែរ!!ផ្ទះ វត្តអីវ៉ាន់ឆេះចោល គេដុតចោលគេវ៉ៃចោលទៅ!!

កៈ ក្នុងជំនាន់លន់ នល់សោះហ្នឹង?

ខៈ បាទ!!

កៈ ក៏ត្រូវ!!

ខៈ គេទំលាក់គ្រាប់មក គេទំលាក់គ្រាប់មក!!ហើយគេផ្លោងអញ្ចេះមកវាមិនត្រូវ!!

កៈ ចាំ!!

ខៈ និយាយរួមពីយើងព្រៃទទឹងទៅយើងនេះហិ!!

កៈ ហ្នំ!!

ខៈ ផ្លោងទៅឆេះផ្ទះឆេះអីអញ្ចឹងទៅណាស់!!

កៈ អាមានអាផ្លោង អាទំលាក់ពីលើណោះផង មានអាអ្នកទំលាក់ពីណោះទៀត?

ខ៖  បាទ!!

ក៖ អញ្ចឹងមានពីរ បី តង់ពូណោះ?

ខ៖   បាទ!!

ក៖ ហើយពូមានដឹងពីគោលបំណងថាអាទំលាក់ហ្នឹង
វាមានគោលបំណងសំលាប់អ្នកណាគេអីអត់?

ខ៖  ប្រជាជន។

ក៖ ទៅសម្លាប់ប្រជាជនវិញអត់ដឹងខ្យល់អីផងហ្នឹង!!

ខ៖   ហ្នឹងសំលាប់ប្រជាជន កងទ័ពអីអញ្ចឹងទៅណាស់!!សម្លាប់ទ័ពអាពតហ្នឹង!!

ក៖ ហ្ហ៎!!អញ្ចឹងមកពីពីមុនវាមានបក្សច្រើនអីហ្នឹងពូណោះ បែងចែកជាមួយលន់ នល់
ជាមួយខ្មែរក្រហមអីអញ្ចឹងទៅ?

ខ៖  បាទបាទ!!

ក៖ អូយ
អានិតណាស់ពូអើយ!!ម៉េចដែរពូគ្រួសារអីវ៉ាន់ហ្នឹងមើលទៅទិដ្ឋភាពពេលហ្នឹងវេទនាខ្លាំងទេពូ?

ខ៖  វេទនា។

ក៖ វាម៉េចខ្លះទៅម៉ែឪពុកអីចឹង?

ខ៖   យើងខ្វះខាតអីចឹងទៅដូចថាយើងហូបរបស់គេវាអត់សូវ វាអត់បានគ្រប់គ្រាន់!!

ក៖  លន់ នល់ហា៎??លន់ នល់ វានៅស្រួលទេពូហី?

ខ៖   ហ្ហ៎លន់ នល់វាបានហូបបាយបានខ្លះហើយ យើងធ្វើស្រែយើងអាចហូបបាយបាន។ក៖
ចា៎!!ខ៖  បើយើងពីជំនាន់អាពតយើងហូបបានតែបបរទេ!!

កៈ ហ្នឹងហើយ ពូតែពេលជំនាន់ លន់
នល់មានដែលអ្នកនៅជិតខាងអីវ៉ាន់មានអ្នកណាគេទំលាក់គ្រាប់អីវ៉ាន់ត្រូវ
ត្រូវគ្រាប់ស្លាប់អីវ៉ាន់អីអត់?

ខៈ  ត្រូវខ្លះដែរត្រូវត្រង់សេ។

កៈ  ហ៊ីហើយអញ្ចឹងម៉េចទៅពូ ម៉ាអាហ្នឹងស្លាប់អស់រលីងទៅហោ?

ខៈ  ស្លាប់អស់ទៅស្លាប់ម៉ា ម៉ាពីរត្រកូលអីវ៉ាន់អញ្ចឹងទៅ!!

កៈ ហ្ហ៎!!

ខៈ ក្នុងត្រង់សេជាមួយគ្នាហ្នឹង!!

កៈ ហ៊ីៗ!!

ខៈ ខ្មោចអស់ទំលាក់ចំពីលើ។

កៈ ឡើងចំម៉ងពូណោះ?

ខៈ  បាទទំលាក់ចំ ឃើញយើងឃើញហុយផ្សែងហុយៗ ។

កៈ ហ្ហ៎!!

ខៈ ឃើញហុយៗហ្នឹងវាទំលាក់ទៅ។

កៈ តែពូ ញ៉ុមឆ្ងល់តែបើសិនជាតែអាហ្នឹង អាហ្នឹងដុះផ្សែងហុយៗហ្នឹងដូចជាអោយគេដឹងតើ!!

ខៈ យើង យើងដាំបាយ។

កៈ ហ្ហ៎!!

ខៈ យើងដាំបាយអញ្ចឹងទៅឃើញផ្សែងហុយគេទំលាក់មកទៅណាស់!!

កៈ ហ៊ីៗ!!

ខៈ គេឃើញយើងហុយៗ!!

កៈ ចាំ!!

ខៈ យើងដាំណាអត់ឃើញមើលកប៉ាលហោះហាំ!!

កៈ ហ៊ឺៗ!

ខៈ បើយើងឃើញកប៉ាល់ហោះមកយើងកុំទាន់ដាំទៅ
បើថាអត់មកអ៊ីចឹងយើងដាំអោយហើយទៅ!!ដាំទុកទៅទុកចោលទៅ!!

កៈ ចាំ បើដាំធ្យូងអត់អីទេពេលហ្នឹងហិ!!

ខៈ បាទដាំអុស។

កៈ តែពេលហ្នឹង!!

ខៈ មានធ្យូងណាពេលហ្នឹង កាលជំនាន់ហ្នឹងមានធ្យូងណាយើងមានតែដាំអុស។

កៈ ហ៊ឺពីមួយជំនាន់ទៅមួយជំនាន់វាប្រែប្រួលអស់ច្រើនណាស់ពូណោះ?

ខៈ បាទ!!

កៈ ពូចូលដល់ជំនាន់ប៉ុល ពតវិញអាថ្ងៃដំបូងនៃជំនាន់ប៉ុលពតពូចាំអីគេខ្លះ?

ខៈ ចាំ ញ៉ុមចាំញ៉ុមរត់ទៅស្រុកគេដល់ភ្នំតាម៉ៅភ្នំអីណោះ!!កៈ ហ្ហ៎!!ខៈ បរទេសទៅ។

កៈ អ៊ីចឹងពូរត់ទៅខេត្តតាកែវវិញ?

ខៈ បាទគេជំលៀសទៅខាងហ្នឹង!!

កៈ ចាំ!!

ខៈ ព្រោះយើងមកខាងណោះយើងមកអត់កើតទេព្រោះយើង
គេជំរុញមកពីនេះទៅហិ!!ពីយើងព្រៃទទឹងទៅ!!

កៈ ហ្ហ៎អញ្ចឹងភាគច្រើនពួកវាច្រានមកមកៗអញ្ចឹងមក!!

ខៈ បាទ!!!ច្រានមកអញ្ចឹងៗ!!

កៈ អាខ្លះទៅអញ្ចុះៗៗទៅ?

ខៈ បាទ!!

កៈ អាខ្លះទៅខាងលើអាខ្លះមកខាងក្រោម!!អីចឹងទៅណោះពូណោះ?

ខៈ បាទ!!ញ៉ុមទៅដល់ខេត្តតាកែវ ដល់កំពង់ស្ពឺ!!

កៈ ហ្ហ៎!!

ខៈ ដល់ភ្នំស្រង់ភ្នំអីណោះ!!

កៈ អញ្ចឹងពីទីតាំងដែលពូនៅជាអចិន្ត្រៃយ៍ម៉ងពេលនៅជំនាន់ប៉ុល ពតពូនៅណាវិញ?

ខៈ  នៅខេត្តតាកែវ។

កៈ  តាកែវ!!គេហៅស្រុកអីគេវិញពូនៅហ្នឹង??

ខៈ  នៅវត្តភព!!

កៈ វត្តអីគេ?

ខៈ  វត្តភោគ។

កៈ វត្តភោគ?

ខៈ  បាទ!

កៈ ពូនៅចាំទាល់តែឥឡូវតើហី?

ខៈ ចាំ!!

កៈ អោយទៅរកទៅរកឃើញទេពូ?

ខៈ ថីរកនឹងឃើញ!!

កៈ អនុស្សាវរីយ៍ដល់សែនពិបាកវេទនាជូរចត់ ពូណោះ?

ខ៖  បាទ!!

ក៖ ចាំអ៊ីចឹងពូសំរាប់ពេលវេលាគេជំលៀសទៅវាម៉េចដែរ ដំបូងឡើយគេប្រាប់ថាម៉េចទៅបានយើងត្រូវចេញអីពីផ្ទះយើង?

ខ៖  យើងទៅទៅគ្រាប់ផ្លោងមក!!យើងចេះតែរត់ទៅ!!

ក៖ ខ្លាំងម៉ងពូហោពេលហ្នឹង?

ខ៖   បាទ!!ចេះតែរត់រត់ទៅចេះតែបរទេះទៅ!!នាំកូនទៅអ៊ីចឹងទៅ!!ហានាំបងប្អូនទៅចេះតែរត់ទៅ!!

ក៖ គ្រប់គ្នាអញ្ចឹងទាំងអស់ពូហោ?

ខ៖   បាទ!!អស់មួយភូមិ មិនមែនទេភូមិយើងទេ ភូមិគេភូមិអីចេះទៅដូចតែគ្នាហ្នឹងអញ្ចឹងទៅ!!

ក៖ អូយ!!ពូបើនឹកឃើញពីសម័យហ្នឹងបើ
ញុំមទាន់ឥវ៉ាន់អញ្ចឹងញុំមមិនដឹងអាណោចអាធម្មខ្លួនប៉ុណ្ណាទេ!!

ខ៖   ហើយខ្មោចអីវ៉ាន់នៅតាមផ្លូវហ្នឹងចេះ!!អត់ទេអត់មានអារម្មណ៍ថាខ្លាចថាអីទេ!!

ក៖ លែងខ្លាចខ្មោចលងអស់?

ខ៖  បាទ!!លែងខ្លាចហើយអីអស់ហើយ!!

ក៖ អស់វាហួសសម័យនឹងខ្លាចខ្មោចលងហើយដោយសារជំនាន់ហ្នឹងទៅ
មិនដឹងអាណាលងអាណាពូហោ?

ខ៖  បាទ!!

ក៖ ពូមានបងប្អូនណាស្លាប់ទេនៅក្នុងជំនានន់ប៉ុល ពតហាំ??

ខ៖  អត់!

ក៖ ជីដូនមួយអីវ៉ាន់?

ខ៖  ជីដូនមួយមាន។

ក៖ ម៉េចដែរពូគាត់ស្លាប់ដោយសារគេ?

ខ៖  គេយកទៅសម្លាប់។

ក៖ ចុះការអត់អាហារម៉េចដែរ?

ខ៖ អត់អាហារដូចថាយើងរែកដីអញ្ចឹងទៅឡើងទៅយើងស្លាប់នឹងដីហ្នឹងទៅ!!

ក៖ ដោយសារបាក់កំលាំងហ្នឹងពូហេ?

ខ៖ អត់មានអីហូបគ្រប់គ្រាន់។

ក៖ ពូពេលពូគិតថាពូពិបាកបំផុតនៅក្នុងជំនានន់ប៉ុល ពតវាម៉េចវិញទៅ?

ខ៖ រកអីប្រៀបធៀបមិនបានទេនៅកាលពីជំនាន់ហ្នឹង!!

ក៖ អ្នកនៅពេលជំនាន់ហ្នឹងបានយល់ពីជំនាន់ហ្នឹងហេ?

ខ៖ បាទ!!ពិបាកណាស់ និយាយនិយាយអត់ចេញទេ!!

ក៖ ម៉េចទៅ ពូនិយាយអោយចេញមើល?

ខ៖ វាពិបាក ពិបាកមែនទែនម៉ងហ្នឹងហា៎!!

ក៖ និយាយថាពូពិបាកមូលហេតុអីគេខ្លះទៅ ពូនិយាយត្រួសៗមើល??

ខ៖  គឺហូបមិនបានគ្រប់គ្រាន់ហ្នឹងហា៎!!

ក៖ ចា៎!!

ខ៖
ហើយយើងសំលៀកបំពាក់អីហ្នឹងហា៎!!យើងហូបអត់បានគ្រប់គ្រាន់យើងពិបាកអីចឹងទៅណាស់ទៅ !!

ក៖ ហ្ន៎!!

ខ៖  បាទ!!

ក៖ ពូពេលហ្នឹងពូហូបអីគេខ្លះពូប្រាប់មើល?

ខ៖  ហូបបបបរហូបគល់ចេកអីអញ្ចឹងទៅ!!

ក៖ ភាគច្រើនមួយៗភាគច្រើនដូចតែគ្នាអ៊ីចឹងម៉ងពូណោះ?ខ៖  បាទ!!

(មិត្តភក្តិ)៖ ដើមចេកវាសំបូរ!!

ខ៖  វាសំបូរ បបរដាក់លាយជាមួយដើមចេកអញ្ចឹងទៅ!!អាដើមចេកយើង!!

ក៖ ចាំ!!

ខ៖  ជូនកាលព្រលិតយើងអញ្ចឹង ស្លរហូបអោយតែបានតឹងៗពោះអញ្ចឹងទៅ!!

ក៖ ធ្វើម៉េចកុំអោយតែតឹងពោះអីវ៉ាន់អញ្ចឹងទៅពូហេ?

ខ៖  បាទ!!

ក៖ ពូពេលនៅជំនានន់ប៉ុល ពតរូបរាងកាយម៉េចដែរទៅពូណោះ ស្គម ឬក៏ម៉េចដែរ?

ខ៖  ស្គម តែល្វៃដូចគ្រោងអញ្ចឹង!!

ក៖  គ្រប់គ្នាអញ្ចឹងទាំងអស់មែនពូ?

ខ៖  បាទ!!!ដូចតែគ្នាហ្នឹង។

ក៖ អត់មានអ្នកណាគេធាត់អីមួយទេពូហេ?

ខ៖  អត់មានអ្នកណាគេធាត់ទេ ធាត់គេយកទឹម!!គេយកទឹមហាំ!!ក៖ អូយ!!ខ៖  គេយកទឹម!!

ក៖ ចុះគោម៉េចទៅ?

ខ៖  គោក៏ទឹមមនុស្សក៏ទឹម មើលតែអាណាធាត់យកមកទឹមមក។

ក៖ ចំ!!អោយអូសអញ្ចឹងទៅ?

ខ៖  បាទ!!

ក៖ អាក្រក់ម្លេះពូអើយ!!

ក៖ ចងខ្សែដូចគោអញ្ចឹងហើយវៃដូចគោអញ្ចឹង!!

ក៖ ហ៊ឺ!!!ហើយអ្នកណាគេអ្នកព្យួរ?

ខ៖  ព្យួរពួកមេហ្នឹងពួកមេមេហ្នឹង ព្យួរទៅវ៉ៃយើងអ៊ីចឹងទៅ!!

ក៖ ចំ សាហាវម្លេះ!!

ខ៖  ព្យួរទៅវ៉ៃយើងអញ្ចឹងទៅ!

ក៖ ចំសាហាវម្លេះ។

ខ៖  ចងខ្សែដូចយើងដូចគោអញ្ចឹងទៅ!!យើងទាញអ៊ីចឹងទៅ!!

ក៖ ដល់ថ្នាក់ហ្នឹងផង?

ខ៖  បាទ!!

ក៖ អាក្រក់ខ្លាំងម៉ងហាំ!!

ខ៖  បាទ!!

ក៖ វាធ្វើម៉េច ហើយពូអានាក់ធ្វើអញ្ចឹងអ្នកនៅក្នុងស្រុកភូមិហ្នឹងឬក៏អ្នកមកពីណាវិញ?

ខ៖   នៅស្រុកគេហ្នឹងនិយាយរួម នៅក្នុងភូមិយើងខ្លះនៅក្នុងភូមិគេខ្លះទៅ!!

ក៖ ដូចគេបញ្ជាពីលើមកម៉ងពូណេះ?

ខ៖  បាទ!!បើថាយើងអត់ធ្វើយើងងាប់ គេថាខ្មាំង!!

ក៖ អញ្ចឹងតែបញ្ជាអីត្រូវធ្វើពូហេ?

ខ៖  បាទ!!

កៈ ចំសាហាវម្ល៉េះហើយពូមានឃើញផ្ទាល់ភ្នែកថាគេទឹមហ្នឹងអត់?

ខៈ  ទាន់។

កៈ ឃើញម៉ងហោ?

ខៈ  ចុះញ៉ុមទឹមតែប៉ុណ្ណឹងញ៉ុមទាន់។

កៈ អូយម៉េចទៅពូ?

ខៈ  ពេលញ៉ុមដើររើសអាចមន៍គេពេលញ៉ុមដើរកាត់ផាងខេត !!

កៈ ហ៊ឺ!!

ខៈ  ញ៉ុមទាន់។

កៈ កុមារគឺកាត់តែប៉ុន្នានហ្នឹងម៉ងពូណោះ?

ខៈ   បាទ!!អត់មានបានរៀនសូត្រអីទេ។

កៈ ហើយគេមានសាលាគេមានអីគេទេ?

ខៈ   ហ៊ឺមានអ្នកណាអោយរៀន
គេយកអ្នកចេះដឹងយកទៅសម្លាប់ចោលហ្នឹង!!អោយតែថាយើងចេះអក្សរគេយកយើងទៅសម្លាប់ចោល។

កៈ ចាំ!!

ខៈ  អត់មានអោយចេះទេ!!

កៈ សាហាវណាស់ពួកអាអស់នេះពូ!!ពូ
ពូធ្លាប់ឃើញគេយកមនុស្សទៅសម្លាប់ចោលដែរតើពូហោ?

ខៈ  ធ្លាប់។

កៈ ម៉េចទៅពូ ពូប្រាប់តិចមើលវាសាហាវប៉ុណ្ណាទៅ?

ខ៖
គេយកយើងយកទៅយកទៅដាក់នៅក្នុងរណ្ដៅហ្នឹងទៅ!!វៃជូនកាលវៃត្បូងចបអីទៅជូនកាលគល់ឬស្សីទៅ។

(មិត្តភក្តិ)៖ដែលលបមើលឃើញគេដែរតើហេ?

ខ៖  ឃើញ!!ជូនកាលផាងត្នោតយើងហ្នឹងអាករអោយទូកៗអញ្ចឹងទៅ!!

ក៖ អូយ!!

ខ៖  ផាងត្នោតយើងអានេះហ្នឹងអាមានបន្លាអាមានអីនោះ!!អាករ។

ក៖ ទំលាក់ចូលរណ្ដៅអីចឹងម៉ងទៅ!!

ខ៖  បាទ!!

ក៖ ពូពេលហ្នឹងថីបានឃើញដើរទៅណាស់វិញ?

ខ៖  ញ៉ុមដើររើសអាចមន៍គោ។

ក៖ ហើយពួកវាឃើញពូដែរ?

ខ៖  គេអត់ឃើញព្រោះញ៉ុមលបមើល។

ក៖ លបមើលទេអញ្ចឹងហេ?

ខ៖  បាទ!!

ក៖ ពួកវាអត់ឃើញម៉ងអីចឹង?

ខ៖  បាទ!អត់!!

ក៖ ចំ!!

ខ៖  តែឃើញ តែឃើញយើងក៏យើងអស់នៅរស់ដែរ។

ក៖ ហើយពូដល់ពេលដឹងរឿងហ្នឹងហើយយកទៅប្រាប់អ្នកណាគេអីអត់?

ខ៖ អត់ប្រាប់ ប្រាប់អីបើប្រាប់បែកការថាយើងនេះហ្នឹងយើងយកប្រាប់គេគេយើងយើងសម្លាប់អស់មួយពូជ។

ក៖ អូយ!

ខ៖ យើងអត់ហ៊ានប្រាប់ទេ!!

ក៖ ចាំអញ្ចឹងគេដាក់ទស្សនៈមួយថាដាំដើមគរហ្នឹងហោ??

ខ៖ បាទ!!

ក៖ ចុះឪពុកម្ដាយរបស់ពូគាត់ម៉េចដែរគាត់ពួកគាត់ពិបាកវេទនាម៉េចដែរ?

ខ៖ វេទនាដូចស្គមយើងកំព្រឹងកំព្រឹងដែរហ្នឹង!!

ក៖ ហ៊ឺៗ!!

ខ៖ ដូចតែគ្នាហ្នឹង។

ក៖ អើយពូអើយពូ!!

ខ៖ ញ៉ុមពីប៉ុល ពតហ្នឹងមក!!

ក៖ ចាំ ពេលពូអើរនៅក្នុងជំនាន់ប៉ុលពតហ្នឹងគឺមុខងារគឺគេអោយរើសអាចមន៍គោនឹងកាត់ផាងខេត?

ខ៖ បាទ!!

ក៖ ហ្នឹងហើយ។

ខ៖ ហ្នឹងហើយញ៉ុមនៅក្មេង។

ក៖ អ៊ីចឹងពូ៣ឆ្នាំ ៨ខែនឹង២០ថ្ងៃហ្នឹងគឺធ្វើមួយហ្នឹងរហូតម៉ងពូណោះ?

ខ៖ បាទ!!

កៈ ហើយចុះដល់ពេលអ្នកធំៗហ្នឹងគេអោយធ្វើអីគេវិញខ្លះវិញពូ?

ខៈ  ធំៗគេគ្រាន់តែដើរមកមើលយើង!!

កៈ ហ៊ឺៗ!!

ខៈ  មើលយើងធ្វើដីអីហ្នឹងធ្វើអីអញ្ចឹងទៅ!!

កៈ ពួកអានាក់ធំៗហ្នឹងហោ?

ខៈ  បាទ!!

កៈ ចុះអ្នកដែលរបៀបនេះហា!!ដូចថាវ៉ៃយកណ្តាលហាំ ២០ឆ្នាំ២០ជាងអីវ៉ាន់អីចឹងហាំ!!

ខៈ  វ៉ៃកដី។

កៈ វ៉ៃកដី?

ខៈ  បាទ!!

កៈ គេធ្វើអីគេខ្លះវ៉ៃកដីហ្នឹងពូ?

ខៈ  វ៉ៃកគេធ្វើអោយជីកប្រឡាយជីកស្រះអីអញ្ចឹងទៅ!!

កៈ ចាំ!!

ខៈ  បាទ!!

កៈ

ពូចុះពេលពូពេលហ្នឹងហាំអ្វីដែលការងារអីគេខ្លះដែលពួកគេធ្វើហាំ?ការងារអីគេខ្លះ?ដែលលពួកប្រជាជនធ្វើ?

ខៈ   មានអីមានតែវ៉ៃកដី ស្ទូងដកអីអញ្ចឹង។

កៈ ចុះបន្លែអី ដាំអីៗអត់ទេហោ?

ខៈ  ដាំបន្លែអាហ្នឹងគេដាំផ្សេង ផ្នែកគេផ្សេងអីចឹងទៅ។

កៈ មានតាមមុខងារអីអញ្ចឹងទៅពូហោ?

ខៈបាទ!!ដាំបន្លែអីចឹងទៅ ពេលដូចថា តែគ្រាន់តែទុកអោយពួកវាស៊ីអញ្ចឹងទៅ។កៈ ហ្ហ៎!!ខៈ ហើយយើងអាដើមចេកហ្នឹងហាន់ទាំងកង់ទាំងកង់ដូចជ្រូកអញ្ចឹងទៅ!!

កៈ អោយ អ្នកណាគេអ្នកហាន់អោយវិញ?ពួកខាងចុងភៅហីអី?

ខៈ  ពួកខាងចុងភៅហ្នឹង!!វាហាន់ស្លរអោយយើងអញ្ចឹង។

កៈ ដើមចេកដូចអាយើងបុកអោយលាយដូចជ្រូកហ្នឹងអីចឹងហី?ខៈ  បាទ!!កៈ អីចឹងម៉ងពីហីទាំងចាស់ទាំងអស់ហ្នឹងហី?

ខៈ  បាទ!!

កៈ ចំយក្ស!!

ខៈ  ហាន់ទាំងកង់ទាំងកង់ដាក់ម៉ងហាំ!!

កៈ ចំ!!មិនមែនទូចៗទេហី?

ខៈ  ប្រវែងប្រវែងនេះ ទាំងកង់!!

កៈ ទាំងចាស់ម៉ងពូណោះ?

ខៈ  បាទ!!

កៈ ហើយចុះដល់ពេលពួកវា ពួកវាស៊ីបាយស៊ីអីវាស៊ីនៅមុខយើងអត់ទេពូ?

ខៈ  វាស៊ីវាមានរបស់វាផ្សេង!!

កៈ វាមានផ្ទះមានអី?

ខៈ  វាមានចង្ក្រានបាយរបស់វា!!

កៈ ម៉ាឆ្នាញ់អីចឹងទៅ?

ខៈ  បាទហើយយើងបបរអីចឹងទៅ!!បានមួយខ្ទះដាក់បានអង្ករ៣ កំប៉ុង ៤កំប៉ុងអីហ្នឹងអញ្ចឹង។

កៈ ចាំរោងបាយពួកវាហើយយើងដាច់ឆ្ងាយពីគ្នាទេពូអត់អោយឃើញគ្នាម៉ងពូហេ?

ខៈ របបវានៅវត្តហ្នឹងម៉ង!!

កៈ ហ្ហ៎!!

ខៈ លោកអត់មានទេ។

កៈ ចាំ!!

ខៈ បបរនៅវត្ត។

កៈ ហើយដល់ពួកវាមានផ្ទះមានអីអញ្ចឹងទៅពូណេះ?

ខៈ វានៅនៅហ្នឹងវត្តិហ្នឹងម៉ង!!

កៈ ពួកអាពតហ្នឹងនៅនឹងវត្តដែរ?

ខៈ បាទ!!ហើយយើងនៅជិតៗវត្តហ្នឹង គេធ្វើរោង។

កៈ វាវាធ្វើរោង គេធ្វើរោងអោយយើងដេកដង្ហែរគ្នាអីចឹងទៅ!!

កៈ ហ៊ឺ!!

ខៈ អាណ្ឌកអាណៃល!!

កៈ ដូចមិនដឹងនឹកឃើញម៉េចគេពូបានអីដល់ថ្នាក់ហ្នឹងពូណោះ?

ខៈ វាចង់សម្លាប់យើងអោយដាច់ជាតិខ្មែរហាំ!!

កៈ ចាំ!!

ខៈ តែទៅអត់រួចបានរំដោះទៅ!!

កៈ អូយ!!សាហាវណាស់ពូអើយ!!

ខ៖ ជីកស្រះដាក់ហូបនំបញ្ចុកហើយគេបាន
បានគេមកបានរំដោះទាន់ហ្នឹងកុំអិស្លាប់អស់ហើយប្រជាជនយើងហ្នឹងហ្ន៎!!

ក៖ ហ៊ឺ!!

ខ៖ គេប្រមូលយើងអោយទៅហូបនំបញ្ចុកក្នុងរណ្ដៅហ្ន៎!!

(មិត្តភក្តិ)៖ដូចគ្នាទាំងអស់គិតទៅ!!

ខ៖ បាទ!!គេស្លូរពីភ្នំពេញមក។

ក៖ តែលាយថ្នាំហើយហើយពូណេះ?

ខ៖ បាទលាយថ្នាំហើយហើយ
គេស្លូរនំបញ្ចុកពីភ្នំពេញមកហើយនំបញ្ចុកគេធ្វើនៅស្រែណេះ។ក៖ ហ៊ឺៗ!!

ខ៖ ហើយគេស្លូរពីភ្នំពេញមក មាន ជិតបានហូបហើយហ្នឹង
តែយួនបានទៅរំដោះយើងបានហ្នឹង ទាន់ហ្នឹង។

ក៖ វាម៉េចដែរពូអាទិដ្ឋភាពរំដោះហ្នឹង?ពូគេចូលទៅចូលម៉េចទៅ?

ខ៖ ផ្លោងគ្រាប់ បានផ្លោងគ្រាប់មកយើងរត់ រត់រួចទៅហ្នឹង!!

ក៖ ចាំ!!

ខ៖ ផ្លោងយើងមួយគ្រាប់ៗទៅបានយើងរត់ទៅ។

ក៖ ហ្ន៎អ៊ិចឹងក៏រត់បោះចោលនំបញ្ចុកហ្នឹងយកតែម្ដងពូហោ?

ខ៖ យើងរត់ទៅយើងលែងបានហូបទៀតទៅ។

ក៖ ហ្ន៎ចុះពេលហ្នឹងអត់មានបានចាប់អីយកទៅខ្លះទេហី?

ខ៖ អត់ទេ។

ក៖ រត់អត់ទាន់ម៉ងពូណេះ?

ខ៖  បាទ!!

ក៖ ផាំងៗៗម៉ងពូហោគ្រាប់វា?

ខ៖  បាទ!!

(មិត្តភក្តិ)៖ មានខេតខ្លះបានហូបហាំ!!

ខ៖  បាទនេះអត់ទាន់បានហូបផង ទឹកសំលរយកមកដល់ស្រាប់គ្រាប់ផ្លោងមកនាំគ្នារត់!!ឡើងប្រវៃប្រវ៉ាអាខ្លះងាប់ក្នុងរណ្តៅអ៊ីចឹងទៅ!!

ក៖ ហ៊ឺៗ!!

ខ៖  វាឡើងអត់រួច។

(មិត្តភក្តិ)៖ និយាយទៅហោង!!

ខ៖  បាទ!!ឡើងមកអត់រួចយើងងាប់នៅក្នុងរណ្តៅហ្នឹងទៅ អាណាឡើងរួចបានរួចអ៊ិចឹងទៅ!!

ក៖ ស៊ីនៅក្នុងរណ្តៅវិញ?

ខ៖  បាទ!!ក្នុងរណ្តៅជីកហើយអ៊ីចឹង។

(មិត្តភក្តិ)៖ស៊ីនៅមាត់រណ្តៅហ្នឹង!!

ក៖ ចំសាហាវគ្រប់កន្លែងហ្នឹងអ៊ីចឹងម៉ងហោ??

ខ៖  បាទ!!

(មិត្តភក្តិ)៖វាធ្វើអញ្ចឹងគ្រប់កន្លែងម៉ងហាំ!!

ខ៖  ធ្វើអញ្ចឹង!

ក៖ តែមានអ្នកណាគេឆ្ងល់ទេពូ?ថាហេតុអីអោយហូបនៅមាត់រណ្តៅវិញ?

ខ៖  ដឹងតើដឹងថាចង់សម្លាប់យើង!!

កៈ តែគេចអត់ផុតពូហោ?

ខៈ  បាទ!!

កៈ ម្នាក់ៗក៏ដឹងថាខ្លះហើយហី?

ខៈ  ដឹងដឹងថាអោយយើងងាប់!!

កៈ ហ៊ឺ!!

ខៈ  ដឹងដែរតែគ្រាន់តែថាបានគេមករំដោះទាន់ទៅយើងបានរួចខ្លួនទៅ!!

កៈ ចាំចុះពេលហ្នឹងប្រជាជនមិនព្រមនាំគ្នាព្រួតគ្នាការពារ!!

ខៈ  វារ៉ៃយើងរ៉ៃម៉េចឈ្នះគេ យើងអត់មានអីរត់ផងហ្នឹង។

កៈ ហ្ហ៎!!

ខៈ  យើងរត់ទៅណារួចបើគេសុទ្ធតែខ្សែរយៈរបស់គេហ្នឹង!!

កៈ របៀបថាប្លន់កាំភ្លើងបាញ់ពួកវាវិញអិចឹងហាំ?

ខៈ  ទៅអត់រួច ទៅអត់រួចទេ!!

(មិត្តភក្តិ)ៈមនុស្សដល់ពេលអត់មានអីស៊ីទន់ហាំ!!

ខៈ  តែយើង និយាយរួមស្គមកាព្រីងកាព្រឹង លើកដៃលើកជើងអត់រួចផងហ្នឹង!!ហើយទៅសម្លាប់គេម៉េច!!ហោយគេធាត់ឡើងកាហើរៗហើយយើងដូចកាចាញ់ចេកអញ្ចឹង!!កៈ ហ្ហ៎!!ខៈ  ហើយទៅសម្លាប់គេម៉េច!!

កៈ ហ៊ឺវេទនាណាស់ពូអើយ!!ឃើញទិដ្ឋភាពមួយហ្នឹងសាហាវណាស់ពូ!!

ខៈ  បាទ!!

កៈ មើលពូអាថ្ងៃពេលហ្វបនំបញ្ចុកហើយរត់ទៅដល់ណាវិញពូ?

ខៈ  ទៅចេះតែទៅទៅភ្នំតាម៉ៅអីទៅ។

កៈ ឡើងភ្នំមែនពូ?

ខៈ  បាទ!ហើយដើររកស្លឹកព្រិចស្លឹកអីហូបអញ្ជឹងទៅ!!

កៈ ហ្ហ៎ហើយប៉ុន្តែអញ្ជឹងមានគិតថាអារម្មណ៍នៅក្នុងខ្លួនថារួចខ្លួនអីអត់ពូ?

ខៈ  ថាអត់មានអារម្មណ៍ថាបានរួចខ្លួនផង
ក្រែងលោថាមានទៀត!!បាននេះហើយអីហើយអញ្ជឹងទៅបានរំដោះហើយអញ្ជឹងទៅបានវិលមកស្រុកវិញ។

កៈ ហ៊ឺ!!

ខៈ  បានមករំដោះហើយបានមកស្រុក។

កៈ  គេប្រាប់អោយមកស្រុកវិញមែនពូ?

ខៈ  យើងលបមក។

កៈ ហ្ហ៎!!

ខៈ  លបមកស្រុកអីអ៊ីចឹងទៅ!!

កៈ ពូពេល ពេលគេមករំដោះហ្នឹងមានមនុស្សច្រើនស្លាប់ណាស់ពូហោ?

ខៈ  បាទ!!

កៈ ភាគច្រើនងាប់ពួកទាហានឬក៏ប្រជាជនពូ?

ខៈ  ទាហានក៏ងាប់ប្រជាជនក៏ងាប់ បាទ!!ងាប់។

កៈ លាយគ្នាពូណោះ !!អើយពេលហ្នឹងមិនដឹងរឹកវរប៉ុន្មានទេពូណោះ?

ខៈ  និយាយទៅដូចខ្មោចឆ្កែខ្មោចអីអញ្ជឹងឡើងរាល !!

កៈ ហ៊ឺ!!

ខៈ  ងាប់ពេញព្រៃតាមផ្លូវអ៊ិចឹងទៅ!!

កៈ ចាំ!!

ខៈ ងាប់!!

កៈ អូយ!!មិនចង់ស្រម៉ៃទេពូ ស្រម៉ៃរូបភាពហ្នឹង អាក្រក់ខ្លាំងណាស់!!

ខៈ បាទ!!

កៈ ដូចវាមិនមែនរឿងដែលកុហកហាំវាជារឿងពិតពូហា!!

ខៈ រឿងពិតរឿងកុហកម៉េចបើ !!និយាយថាប្រាប់ក្មេងៗឥឡូវគេអត់ជឿទេ!!

កៈ អត់ជឿហេ?

ខៈ អត់ជឿទេ!!បើក្មេងជំនាន់មុនបានថាវេទនាម៉េចអីអាម៉េច ដឹងថាវេទនា!!កៈ ចាំ!ខៈ ហូបរបៀបម៉េចគល់ឬស្សីអីម៉េច ត្បូងចបអាម៉េច!!

កៈ អើយ!!

ខៈ ផាងត្នោអាម៉េច!!

កៈ តែពូអត់ដែលគេយកទៅណាហី?

ខៈ អត់!!

កៈ ហេងហើយអីចឹង!!

ខៈ ញុំមនៅក្មេង យើងក្មេងគេម៉េចនេះ!!

កៈ អត់!!! រួចខ្លួនអីចឹងទៅពូណោះ?

ខៈ បាទ!!

កៈ តែស្លាប់អ្នកដែលអ្នកនៅក្នុងភូមិដែលពូហ្នឹងនៅអីស្លាប់ច្រើនទេពូ?

ខៈ ស្លាប់ច្រើនដែរ!!

កៈ ហ៊ឺ!!

ខៈ  ស្លាប់អត់បាយអត់ទឹកអីអញ្ចឹងទៅ!!

កៈ ភាគច្រើនគឺអ៊ីចឹងពូហេ?

ខៈ  បាទ!!

កៈ សម្លាប់ភាគតិចឬក៏អីគេពូ?

ខៈ  យកទៅសម្លាប់ខ្លះអត់បាយខ្លះអ៊ិចឹងទៅ!!ដាច់ពោះ!!ដាច់ពោះរឿងបាយ!!

កៈ ហ្នំដើរដួលស្លាប់អ៊ីចឹងទៅពូណេះ?

ខៈ  បាទ!!ដើរៗព្រួសស្លាប់ទៅ!!

កៈ អើយ!!

ខៈ  អត់បាយអត់ទឹកអី!!

កៈ អ៊ិចឹងពូដល់ពេលពូបែកពីជំនាន់ប៉ុល ពតមកតើក្រុមគ្រួសាររកស៊ីអីគេដែរពូ?

ខៈ  ឡើងត្នោតហ្នឹង!!

កៈ តែឡើងត្នោតឪពុកអ៊ិចឹងទៅពូណោះ?

ខៈ  បាទ!!

កៈ ហើយចុះពូរកស៊ីអីគេខ្លះក្នុងជីវិតរបស់ពូ?

ខៈ  ឡើងត្នោតញ៉ុមដាំជំឡូងជាមួយតា!!

កៈ ចាំ!!

ខៈ  បាទ!!!

កៈ ហើយពូរកស៊ីអីគេដែរដល់ពេលមានប្រពន្ធមានកូនមក?

ខ៖ ញ៉ុមធ្វើសំនង់។

ក៖ ហើយក្រៅពីធ្វើការសំនង់ពូមានធ្វើអីគេទៀតទេ!!

ខ៖ មានអីមានតែធ្វើសំនង់ហ្នឹង!!

ក៖ ចាំ!!ទោះចិញ្ចឹមប្រពន្ធមុននឹងចិញ្ចឹមប្រពន្ធក្រោយគឺធ្វើសំនង់ទាំងអស់?

ខ៖ បាទ!!

ក៖ ចុះប្រពន្ធមុនគាត់ធ្វើការអីគេដែរ?

ខ៖ រោងចក្រ។

ក៖ ចុះឥឡូវក្រោយនេះ?

ខ៖ ក្រោយនេះរោងចក្រដែរ!!

ក៖ គាត់ធ្វើរោងចក្រដែរ?

ខ៖ បាទ!!

ក៖ អញ្ចឹងលោកពូដើម្បីអោយក្រុមគ្រួសាររបស់លោកពូមានសុភមង្គលតើពូលះបង់ម៉េចដែរដូចជាប្រពន្ធអីវ៉ាន់កូនអីវ៉ាន់អញ្ចឹងទៅណាស់!!ដឹងហើយថាពូអ្នកត្រូវហើយដោយសារពូអត់មានអ្នកធ្វើដូចថាអត់មានក្បត់ចិត្តមីងពេលមុនហាំ!!

ខ៖ បាទ!!

ក៖ ដោយសារមីងទេជាអ្នកធ្វើមួយហ្នឹងហ្នំ!!

ខ៖ ហ្នឹង!

ក៖ តែសំរាប់ពូតាមគំនិតរបស់ពូដើម្បីអោយក្រុមគ្រួសារមានសុភមង្គលពូបានគិតម៉េចដែរពូ!!

ខ៖ យើងខំរកលុយអោយប្រពន្ធកូនអីចឹងទៅ!!

ក៖ ចាំ!!

ខ៖ បាទ!!

ក៖ ស្រលាញ់ប្រពន្ធកូនអ៊ីចឹងទៅពូណោះ?

ខ៖ ស្រលាញ់ប្រពន្ធកូនអ៊ិចឹងទៅ!!

ក៖ ចាំហ្នឹងហើយ!!ចាំ!!

ខ៖ យកអ៊ិចឹងទៅវិញទៅមកអ៊ិចឹងទៅ!!

ក៖ ហ្នឹងហើយ!!

ខ៖ បាទ!!

ក៖ អូខេ!!ពូមានអីគេទៀតដែលចង់ប្រាប់ចង់អីអត់?

ខ៖ អត់ទេមានតែប៉ុណ្ណឹង!!

ក៖ ឥឡូវមួយនេះគឺជាសំនួរមួយចុងក្រោយ
ពូមានពាក្យពេចន៍អីគេខ្លះដែលចង់ផ្ដែផ្ដាំកូនចៅជំនាន់ក្រោយថាអោយគាត់ដើរលើផ្លូវម៉េចដែរអ៊ីចឹងទៅណាស់ពូហា?

ខ៖ ចង់អោយដើរផ្លូវល្អកុំអោយដើរផ្លូវអាក្រក់និយាយរួម!!

ក៖ ចាំ!!អោយគេចផុតពីអីគេ?

ខ៖ ទេថាតែមួយមុខពីរមុខហ្នឹង!!

ក៖ ទេតែមួយមុខពីរមុខម៉េចពូ?

ខ៖ ថ្នាំញៀនហើយនឹងចោរបាទ!!ហ្នឹងផ្ដាំផ្ញើរតែប៉ុណ្ណឹង!!

ក៖ ចាំអ៊ិចឹងសូមនិយាយថា ទេ គ្រឿងញៀន!!ចាំហ្នឹងហើយ!!

ខ៖ បាទ!!

ក៖ ហ្នឹងហើយអ៊ីចឹងអរគុណលោកពូសំរាប់អើរ!!

ខ៖ បាទ!!

ក៖ ជីវប្រវត្តិរបស់លោកពូនឹងបងប្អូនដូនតាក៏ដូចជាប្រវត្តិសង្គ្រាមរបស់ពូអ៊ីចឹងណាស់!!

ខ៖ បាទ!!

ក៖ ដែលពូបានឆ្លងកាត់ហ្នឹង !!ចាំអ៊ីចឹងអរគុណច្រើនលោកពូ។

ខ៖ បាទ!!